# ក្រសួងអប់រំនៃរដ្ឋកាលីហ្វូនញ៉ា
# លិខិតជាផ្លូវការ

28 សីហា 2015

ជូនចំពោះអគ្គនាយកថ្នាក់សង្កាត់ និងខោណធី, នាយកនៃសាលារៀនឆាតធ្វើស្គូល និងអ្នកសម្របសម្រួលតេស្ត CAHSEE ជាទីគោរព៖

## តម្រូវការឱ្យចូលធ្វើតេស្តបញ្ចប់ការសិក្សាពីវិទ្យាល័យនៃរដ្ឋកាលីហ្វូនញ៉ា ដើម្បីឱ្យទទួលបាននូវសញ្ញាប័ត្រឌីផ្លូម៉ា ត្រូវបានព្យួរសិន សំរាប់សិស្សថ្នាក់ទីដប់ពីរណាដែលមានសិទ្ធិទទួល នៅក្នុងក្រុមសិស្សដែលបានរៀនចប់នៅឆ្នាំ 2015

ពង្រាងច្បាប់ Senate Bill 725 (Hancock) ត្រូវបានចុះហត្ថលេខាដោយអភិបាល និងបានកំណត់លេខរៀងសំគាល់ច្បាប់នេះ នៅថ្ងៃទី 26 ខែសីហា ឆ្នាំ 2015។ ច្បាប់នេះបានផ្អាកការអនុម័តការធ្វើតេស្តបញ្ចប់ការសិក្សាពីវិទ្យាល័យនៃរដ្ឋកាលីហ្វូនញ៉ា (CAHSEE) ទុកជាលក្ខខណ្ឌមួយ ដើម្បីឱ្យអាចទទួលបាននូវសញ្ញាប័ត្រឌីផ្លូម៉ាបញ្ចប់ការសិក្សា ឬជាលក្ខខណ្ឌមួយ ដើម្បីបញ្ចប់ការសិក្សាពីវិទ្យាល័យ សំរាប់សិស្សណាដែលបំពេញបានទៅតាមតម្រូវការនានានៃការបញ្ចប់ការសិក្សាពីវិទ្យាល័យផ្សេងទៀតទាំងអស់ នៅក្នុងឆ្នាំសិក្សា 2014-15។ ភ្នាក់ងារអប់រំតាមមូលដ្ឋាន អាចនឹងចាប់ផ្តើមភ្លាមៗ ក្នុងការផ្តល់សញ្ញាប័ត្រឱ្យសិស្សណាដែលមានសិទ្ធិទទួល។

ច្បាប់ SB 172 (Liu) ដែលបានគាំទ្រដោយក្រសួងអប់រំរដ្ឋកាលីហ្វូនញ៉ា កាលពីខែកុម្ភៈ ឆ្នាំ 2015 ដែលស្នើសុំឱ្យផ្អាកបណ្តោះអាសន្នសិន ចំពោះតម្រូវការធ្វើតេស្ត CAHSEE សំរាប់ឆ្នាំសិក្សា 2015-16, 2016-17 និង 2017-18; ច្បាប់ហ្នឹងក្នុងពេលបច្ចុប្បន្ននេះកំពុងត្រូវបានពិចារណាដោយក្រុមអ្នកតាក់តែងច្បាប់។ ច្បាប់ SB 172 ផ្តល់ឱ្យរដ្ឋកាលីហ្វូនញ៉ាផងដែរ នូវឱកាសបង្កើត និងពិនិត្យលើអនុសាសន៍នានា សំរាប់វិធីសាស្ត្ររៀបចំដាក់គោលការណ៍បញ្ចប់ការសិក្សាដែលមានផលិតភាព ដែលធ្វើឱ្យរដ្ឋកាលីហ្វូនញ៉ា ផ្លាស់ប្តូរឆ្ពោះទៅរកស្តង់ដាខ្ពស់ ដើម្បីជួយឱ្យសិស្សត្រៀមខ្លួនជាស្រេច សំរាប់មហាវិទ្យាល័យ និងអាជីព ហើយនិងអាត្រារៀនចប់ឧត្តមសិក្សា។ យើងខ្ញុំនឹងផ្តល់ព័ត៌មានថ្មីបំផុត អំពីស្ថានភាពនៃច្បាប់ SB 172 នៅពេលដែលចំណាត់ការត្រូវបានចាត់។ លទ្ធផលនៃច្បាប់ទាំងអស់នេះ នឹងត្រូវបានគេដឹងឮគ្រប់គ្នា មិនឱ្យហួសពីថ្ងៃទី 11 ខែតុលាឆ្នាំ 2015 ទេ។

យើងខ្ញុំនឹងផ្តល់ជូនលោកអ្នកនូវព័ត៌មានថ្មីបំផុត នៅពេលដែលរដ្ឋកាលីហ្វូនញ៉ា បន្តផ្លាស់ប្តូរឆ្ពោះទៅរកប្រព័ន្ធវាយតម្លៃ និងប្រព័ន្ធទទួលខុសត្រូវថ្មី ដែលសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងថ្នាក់មូលដ្ឋាន ការកែលំអជាបន្ត និងការរៀបចំសិស្សសាលារបស់យើង ឱ្យទទួលបានជោគជ័យពីមហាវិទ្យាល័យ និងពីការចាប់យកអាជីព។

ប្រសិនបើលោកអ្នកមានសំណួរណាមួយ ទាក់ទងនឹងព័តមាននេះ សូមទាក់ទងការិយាល័យនៃវិទ្យាល័យ និងការិយាល័យវាយតម្លៃលើកីឡាកាយសម្ព័ន្ធ តាមរយៈទូរស័ព្ទលេខ 916-445-9449 ឬតាមរយៈអ៊ីម៉ែល CAHSEE@cde.ca.gov។

ដោយក្តីគោរពស្មោះពីខ្ញុំបាទ,

Tom Torlakson

TT:gp

បានពិនិត្យមើលពីមុន៖ ថ្ងៃសុក្រ ទី 17 កុម្ភៈ 2017